**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**ក្រុមហ៊ុន អិល ប៊ី អិន អេគ្រីខលឈ័រ ឯ.ក**

**និង**

**តំណាងប្រតិភូបុគ្គលិក**

**ក្រុមហ៊ុន អិល ប៊ី អិន អេគ្រីខលឈ័រ ឯ.ក(មេមត់)**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤ វេលាម៉ោង ៩ និង ០០នាទីព្រឹក នៅក្នុងក្រុមហ៊ុន**អិល ប៊ី អិន អេគ្រីខលឈ័រ** ដែលមានអាសយដ្ឋាន ភូមិបេង ឃុំដារ ស្រុក មេមត់ ខេត្តត្បូងឃ្មុំ មានកិច្ចប្រជុំមួយ រវាង តំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត ប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងធ្វើការតាមរដូវកាល ដូច្នេះរដូវកាលនេះ ពុំទាន់សម្ភារវត្ថុធាតុដើមសម្រាប់ផលិត ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់ក្រុមហ៊ុនទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ៤ នាក់ គិតចាប់ពីថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២៤ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ឈ្នួលសម្រាប់កម្មករ និយោជិតម្នាក់ៗ នៅថ្ងៃទី ៥ នៃខែបន្ទាប់។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០ និង ៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាត និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន ។

ត្បូងឃ្មុំ.ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២៤

**តំណាងកម្មករ**

៣១ . ឧសភា ២០២៤

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អិលប៊ីអិន អេគ្រីខលឈ័រ ឯ.ក LBN AGRICULTURE Co.,Ltd. KINGDOM OF CAMBODIA